“ឯកសារនេះត្រូវបានបកប្រែចេញពីឯកសារស្របច្បាប់ដែល HUD បានចេញផ្សាយ ។ HUD ផ្តល់ការបកប្រែនេះជូនអ្នក គឺគ្រាន់តែជាការផ្តល់ភាពងាយស្រួល ដើម្បីជួយអ្នកឲ្យយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកតែប៉ុណ្ណោះ ។ កំណែជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាឯកសារផ្លូវការ ពេញច្បាប់ និង ជាឯកសារបានត្រួតពិនិត្យ ។ ឯកសារដែលបានបកប្រែនេះ គឺមិនមែនជាឯកសារផ្លូវការឡើយ ។

**ក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុងសហរដ្ឋអាមេរិក**
**ការិយាល័យទីលំនៅ ការិយាល័យនៃកម្មវិធីទីលំនៅពហុគ្រួសារ**
គម្រោងកែលម្អសមាហរណកម្មថ្លៃជួលលំនៅដ្ឋាន

# EIV និង អ្នក

ប្រព័ន្ធពិនិត្យបញ្ជាក់ចំណូលបុគ្គល

**អ្វីដែលអ្នកគួរតែដឹង**
**ប្រសិនបើអ្នកកំពុងតែស្នើសុំ ឬកំពុងទទួល**
**ជំនួយថ្លៃជួលលំនៅដ្ឋានតាមរយៈក្រសួងវឌ្ឍនកម្មទីលំនៅ និងទីក្រុង (HUD)**

## តើ EIV ជាអ្វី?

EIV គឺជាប្រព័ន្ធកុំព្យូទ័រនៅលើគេហទំព័រដែលផ្ទុកនូវព័ត៌មានអំពីការងារនិងចំណូលរបស់បុគ្គលទាំងឡាយណាដែលចូលរួមក្នុងកម្មវិធីជំនួយថ្លៃជួលលំនៅដ្ឋានរបស់ HUD ។ ព័ត៌មាននេះជួយ HUD ក្នុងការធ្វើឲ្យប្រាកដថា “អត្ថប្រយោជន៍ដែលត្រឹមត្រូវ ត្រូវបានផ្តល់ជូនអ្នកដែលត្រូវការពិតប្រាកដ”។

## តើព័ត៌មានអំពីចំណូលអ្វីខ្លះដែលមាននៅក្នុង EIV ហើយតើព័ត៌មាននេះចេញមកពីណា?

**រដ្ឋបាលសុខុមាលភាពសង្គម ៖**

ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាពសង្គម
ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាពជាចំណូលបន្ថែម
ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាពសង្គមជាសិទ្ធិទទួលបានទ្វេ

**ក្រសួងសុខាភិបាលនិងសេវាកម្មបំរើប្រជាជន ប្រព័ន្ធទិន្នន័យជាតិនៃការជួលបុគ្គលិកថ្មី ៖**

ប្រាក់ខែ
ប្រាក់ឧបត្ថម្ភពេលអត់ការងារធ្វើ
បុគ្គលិកថ្មី (W-4)

## តើព័ត៌មានដែលមាននៅក្នុង EIV ត្រូវបានប្រើដើម្បីអ្វី?

ប្រព័ន្ធ EIV ផ្តល់ឲ្យអ្នកគ្រប់គ្រងនិង/ឬម្ចាស់អចលនទ្រព្យពីទីកន្លែងដែលអ្នករស់នៅ ជាមួយនឹងព័ត៌មានអំពីចំណូល និងប្រវត្តិការងារ របស់អ្នក។ ព័ត៌មាននេះត្រូវបានប្រើដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវរបស់ HUD ដើម្បីពិនិត្យបញ្ជាក់ពីការងារ និង/ឬចំណូលរបស់ អ្នកដោយឯករាជ្យ នៅពេលដែលអ្នកធ្វើការបញ្ជាក់ឡើងវិញដើម្បីទទួលបានជំនួយថ្លៃជួលផ្ទះជាបន្ត។ ការយកព័ត៌មាននេះចេញពីប្រព័ន្ធ EIV គឺមានភាពត្រឹមត្រូវជាង និងចំណាយពេលតិចជាង ហើយអស់ថ្លៃចំណាយតិចជាងចំពោះអ្នកគ្រប់គ្រងឬម្ចាស់អចលនទ្រព្យនៅពេលធ្វើការទំនាក់ទំនងយកព័ត៌មានស្តីពីចំណូលរបស់អ្នកដោយផ្ទាល់ដើម្បីធ្វើការពិនិត្យបញ្ជាក់នេះ។

អ្នកគ្រប់គ្រងនិងម្ចាស់អចលនទ្រព្យអាចប្រើប្រាស់ប្រព័ន្ធ EIV ដើម្បីកំណត់ថាតើអ្នក៖

- បានរាយការណ៍ពីចំណូលរបស់អ្នកដោយត្រឹមត្រូវដែរឬទេ?

ពួកគេក៏នឹងអាចកំណត់ថាតើអ្នក៖

បានប្រើលេខសុខុមាលភាពសង្គម ក្លែងក្លាយដែរឬទេ?
មិនបានរាយការណ៍ ឬរាយកាណ៍មិនគ្រប់ពីចំណូលរបស់ប្តី/ប្រពន្ធ ឬសមាជិកគ្រួសារផ្សេងទៀតដែរឬទេ?
ទទួលបានជំនួយថ្លៃជួលផ្ទះនៅលើទីតាំងអចលនទ្រព្យមួយផ្សេងទៀតដែរឬទេ?

## តើត្រូវតែមានការព្រមព្រៀងពីសំណាក់ខ្ញុំដែរឬទេក្នុងការយកព័ត៌មានទាក់ទងអំពីខ្ញុំចេញពី EIV?

ពិតជាត្រូវមាន។ នៅពេលអ្នកចុះហត្ថលេខាលើទម្រង់បែបបទ HUD-9887 ស្តីពីកំណត់សម្គាល់និងការយល់ព្រមសម្រាប់ការចេញផ្សាយ ព័ត៌មាន និងទម្រង់បែបបទ HUD-9887-A ស្តីពីការយល់ព្រមរបស់ អ្នកដាក់ពាក្យ/អ្នកជួលលំនៅដ្ឋានចំពោះការចេញផ្សាយព័ត៌មាននេះ មានន័យថាអ្នកផ្តល់ការយល់ព្រមរបស់អ្នកឲ្យ HUD និងអ្នកគ្រប់គ្រង ឬម្ចាស់អចលនទ្រព្យទទួលបានព័ត៌មានអំពីអ្នកដើម្បី ធ្វើការពិនិត្យបញ្ជាក់ពីការងារ និង/ឬចំណូលរបស់អ្នក ហើយកំណត់អំពីសិទ្ធិរបស់អ្នកក្នុងការទទួលបានជំនួយថ្លៃជួលផ្ទះពី HUD។ ប្រសិនបើអ្នកមិន ចុះហត្ថលេខាលើទម្រង់បែបបទទាំងនេះទេ អ្នកអាចប្រឈមទៅនឹងការបដិសេធក្នុងការផ្តល់ជំនួយ ឬការបញ្ចប់ការ ឧបត្ថម្ភលើថ្លៃជួលផ្ទះ។

## តើនរណាអាចចូលមើលព័ត៌មាននៅក្នុង EIV បាន?

មានតែអ្នកនិងបណ្តាភាគីដែលមានរាយឈ្មោះនៅលើទម្រង់បែបបទ HUD-9887 ដែលអ្នកត្រូវចុះហត្ថលេខាប៉ុណ្ណោះ ទើបមានសិទ្ធិ អាចចូលមើលព័ត៌មាននៅក្នុង EIV ដែលពាក់ព័ន្ធនឹងអ្នកបាន។

## តើការទទួលខុសត្រូវរបស់ខ្ញុំមានអ្វីខ្លះ?

ក្នុងនាមជាអ្នកជួលអចលនទ្រព្យដែលត្រូវបានផ្តល់ជាជំនួយដោយ HUD អ្នកត្រូវបញ្ជាក់ថាព័ត៌មានដែលបានសរសេរនៅលើពាក្យស្នើសុំ ជំនួយថ្លៃជួលផ្ទះ និងនៅលើទម្រង់បែបបទដែលត្រូវបានប្រើដើម្បីបញ្ជាក់ និងបញ្ជាក់ឡើងវិញពីជំនួយរបស់អ្នក (ទម្រង់បែបបទ HUD-50059) ពិតជាត្រឹមត្រូវ និងស្មោះត្រង់។ ប្រការនេះក៏មានរៀបរាប់នៅក្នុងសៀវភៅណែនាំអំពី*សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក ជួលលំនៅដ្ឋាន* ហើយអ្នកគ្រប់គ្រង ឬម្ចាស់អចលនទ្រព្យត្រូវបានតម្រូវឲ្យផ្តល់សៀវភៅនេះ ជូនដល់អ្នកជារៀងរាល់ឆ្នាំ។

### ការពិន័យទោសចំពោះការផ្តល់ព័ត៌មានមិនពិត

ការផ្តល់ព័ត៌មានមិនពិតគឺជាការបោកបញ្ឆោត។ ការពិន័យទោសចំពោះអ្នកទាំងឡាយណាដែលប្រព្រឹត្តការបោកបញ្ឆោតអាចរួមមាន ការបណ្តេញចេញ ការទូទាត់សងវិញនូវប្រាក់ជំនួយលើសដែលបានទទួល ការពិន័យជាប្រាក់រហូតដល់ $10,000 ការដាក់ពន្ធនាគារ រហូតដល់ 5 ឆ្នាំ ការហាមមិនឲ្យទទួលជំនួយថ្លៃជួលផ្ទះនៅពេលក្រោយៗទៀត និង/ឬការពិន័យទោសពីរដ្ឋាភិបាលក្នុងតំបន់និងរដ្ឋ។

### ដើម្បីការពារខ្លួនអ្នក សូមធ្វើតាមលក្ខខណ្ឌដែលតម្រូវអោយមាននៅក្នុងការរាយការណ៍របស់ HUD

នៅពេលបំពេញពាក្យស្នើសុំ និងការបញ្ជាក់ឡើងវិញ អ្នកត្រូវតែរួមបញ្ចូលប្រភពចំណូលទាំងអស់ដែលអ្នក ឬសមាជិកណាម្នាក់នៃ គ្រួសារអ្នកទទួលបាន។ ប្រភពមួយចំនួនមានដូចជា៖

ចំណូលពីប្រាក់ខែ
ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាព
ប្រាក់ឧបត្ថម្ភពេលអត់ការងារធ្វើ
ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាពសង្គម ឬ ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាពជាចំណូលបន្ថែម
ប្រាក់ឧបត្ថម្ភសម្រាប់អតីតយុទ្ធជន
សោធន ប្រាក់ចូលនិវត្តន៍ ។ល។
ចំណូលពីទ្រព្យសកម្ម

បាក់ទទួលបានក្នុងនាមតំណាងឲ្យកូន ដូចជា៖

- *ប្រាក់ឧបត្ថម្ភកុមារ*
- *ប្រាក់ឧបត្ថម្ភពី AFDC*
- *ប្រាក់ឧបត្ថម្ភផ្នែកសុខុមាលភាពសម្រាប់កុមារ ។ល។*

ប្រសិនបើអ្នកមានចម្ងល់ចង់ដឹងថាតើប្រាក់ដែលទទួលបានគួរតែរាប់បញ្ចូលជាចំណូលឬអត់នោះ សូមសាកសួរអ្នកគ្រប់គ្រង ឬម្ចាស់អចលនទ្រព្យដែលអ្នកជួល។

នៅពេលមានការផ្លាស់ប្តូរកើតឡើងចំពោះចំណូលគ្រួសារ ឬសមាសភាពគ្រួសាររបស់អ្នក សូមទាក់ទងអ្នកគ្រប់គ្រង ឬម្ចាស់អចលនទ្រព្យដែលអ្នកបានជួលភ្លាមៗ ដើម្បីកំណត់ថាតើការផ្លាស់ប្តូរនេះនឹងប៉ះពាល់ដល់ជំនួយថ្លៃជួលផ្ទះរបស់អ្នកដែរឬទេ។

អ្នកគ្រប់គ្រង ឬម្ចាស់អចលនទ្រព្យដែលអ្នកបានជួល ត្រូវបានតម្រូវឲ្យផ្តល់ឲ្យអ្នកនូវឯកសារចម្លងនៃក្រដាសព័ត៌មានណែនាំអំពី “របៀបដែលថ្លៃជួលផ្ទះរបស់អ្នកត្រូវបានកំណត់” ដែលរួមមានការរាយរៀបរាប់ពីអ្វីដែលរួមបញ្ចូល ឬដកចេញពីចំណូល។

## តើខ្ញុំត្រូវធ្វើអ្វី ប្រសិនបើខ្ញុំមិនយល់ស្របនឹងព័ត៌មានក្នុង EIV?

ប្រសិនបើអ្នកមិនយល់ស្របជាមួយនឹងព័ត៌មានអំពីចំណូលនិង/ឬការងារនៅក្នុង EIV អ្នកត្រូវតែប្រាប់អ្នកគ្រប់គ្រង ឬម្ចាស់ចលនទ្រព្យដែលអ្នកបានជួល។ អ្នកគ្រប់គ្រង ឬម្ចាស់ចលនទ្រព្យដែលអ្នកបានជួលនឹងទាក់ទងទៅកាន់ប្រភពចំណូលដោយផ្ទាល់ដើម្បីទទួល បានការពិនិត្យបញ្ជាក់ពីការងារនិង/ឬចំណូលដែលអ្នកមិនយល់ស្របនោះ។ នៅពេលដែលអ្នកគ្រប់គ្រង ឬម្ចាស់ចលនទ្រព្យទទួលបានព័ត៌មានពីប្រភពចំណូលនេះហើយ អ្នកក៏នឹងត្រូវបានជូនដំណឹងជាលាយល័ក្ខអក្សរអំពីលទ្ធផលនេះដែរ។

## តើខ្ញុំត្រូវធ្វើអ្វី ប្រសិនបើពីមុនខ្ញុំមិនបានរាយការណ៍ពីចំណូល ហើយឥឡូវព័ត៌មាននេះត្រូវបានរាយការណ៍នៅក្នុង EIV?

ប្រសិនបើរបាយការណ៍ EIV បង្ហាញពីចំណូលនៅអំឡុងពេលមុនដែលអ្នកមិនបានរាយការណ៍នោះ អ្នកមានជម្រើសពី៖ 1) អ្នកអាចយល់ស្របជាមួយនឹងរបាយការណ៍ EIV ប្រសិនបើវាត្រឹមត្រូវ ឬ 2) អ្នកអាចជំទាស់នឹងរបាយការណ៍នេះ ប្រសិនបើអ្នកជឿជាក់ថាវា មិនត្រឹមត្រូវ។ បន្ទាប់មកអ្នកគ្រប់គ្រង ឬម្ចាស់ចលនទ្រព្យក្នុងនាមជាភាគីទីបីនឹងធ្វើការពិនិត្យបញ្ជាក់ជាលាយល័ក្ខអក្សរជាមួយនឹងប្រភពចំណូលដែលបានរាយការណ៍នោះ។ ប្រសិនបើប្រភពបញ្ជាក់ថាចំណូលនេះគឺត្រឹមត្រូវ អ្នកនឹងត្រូវតម្រូវឲ្យទូទាត់សងវិញនូវរាល់ប្រាក់ជំនួយថ្លៃជួលផ្ទះដែលបានបង់លើសក្នុងអំឡុងពេលរហូតដល់ប្រាំ(5) ឆ្នាំ ហើយអ្នកអាចនឹងប្រឈមនឹងការពិន័យទោស ប្រសិនបើគេ រកឃើញថាអ្នកមានចេតនាព្យាយាមបិទបាំងចំណូលរបស់ខ្លួន។

## តើខ្ញុំត្រូវធ្វើអ្វី ប្រសិនបើព័ត៌មានក្នុង EIV មិនមែននិយាយអំពីខ្ញុំ?

EIV មានសមត្ថភាពរកមុខបណ្តាករណីនៃការលួចអត្តសញ្ញាណដែលអាចកើតមាន។ នរណាម្នាក់កំពុងប្រើប្រាស់លេខសុខុមាលភាពសង្គមរបស់អ្នក។ ប្រសិនបើករណីបែបនេះត្រូវបានរកឃើញ អ្នកត្រូវតែផ្តល់ដំណឹងដល់រដ្ឋបាលផ្នែកសុខុមាលភាពសង្គម ដោយទូរស័ព្ទទៅពួកគេតាមរយៈលេខ 1-800-772-1213 ដែលឥតគិតថ្លៃ។ ព័ត៌មានបន្ថែមអំពីអត្តសញ្ញាណអ្នកលួច មានផ្តល់ជូននៅលើគេហទំព័ររបស់រដ្ឋបាលផ្នែកសុខុមាលភាពសង្គម ដែលមានអាសយដ្ឋាន http://www.ssa.gov/pubs/10064.html។

## តើខ្ញុំត្រូវទាក់ទងនរណា ប្រសិនបើជំនួយថ្លៃជួលផ្ទះ ឬចំណូលរបស់ខ្ញុំត្រូវបានគណនាដោយមិនត្រឹមត្រូវ?

ជាដំបូង សូមទាក់ទងអ្នកគ្រប់គ្រងឬម្ចាស់អចលនទ្រព្យដែលអ្នកជួលដើម្បីសុំការពន្យល់។

ប្រសិនបើអ្នកត្រូវការជំនួយបន្ថែម អ្នកអាចទំនាក់ទំនងមកអ្នកចាត់ចែងកិច្ចសន្យាសម្រាប់អចលនទ្រព្យដែលអ្នករស់នៅ ហើយប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយឲ្យអ្នកពេញចិត្តទេនោះ អ្នកអាចទាក់ទងមក HUD។ សម្រាប់ជំនួយក្នុងការរកទីតាំងការិយាល័យ HUD ដែលនៅជិតអ្នកបំផុតដែលអាចផ្តល់ព័ត៌មានទំនាក់ទំនងដល់អ្នកសម្រាប់ទាក់ទងអ្នកចាត់ចែងកិច្ចសន្យា សូមទូរស័ព្ទមកកាន់មជ្ឈមណ្ឌលប្រមូលព័ត៌មានពីទីលំនៅពហុគ្រួសារ តាមរយៈលេខ 1-800-685-8470 ។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមអំពី EIV និងដំណើរការពិនិត្យបញ្ជាក់ពីចំណូលនៅកន្លែងណា?

អ្នកគ្រប់គ្រង ឬម្ចាស់អចលនទ្រព្យដែលអ្នកជួលអាចផ្តល់ឲ្យអ្នកនូវព័ត៌មានបន្ថែមអំពី EIV និងដំណើរការពិនិត្យបញ្ជាក់ពីចំណូល។ ពួកគេក៏អាចណែនាំឲ្យអ្នកទៅជួបអ្នកចាត់ចែងកិច្ចសន្យាដែលសមស្រប ឬការិយាល័យ HUD ក្នុងតំបន់របស់អ្នកដើម្បីទទួលបាន ព័ត៌មានបន្ថែម។

ប្រសិនបើអ្នកអាចរកកុំព្យូទ័រប្រើបាន អ្នកអាចអានព័ត៌មានបន្ថែមពី EIV និងដំណើរការពិនិត្យបញ្ជាក់ពីចំណូលនៅលើគេហទំព័រ EIV ពហុគ្រួសាររបស់ HUD ដែលមានអាសយដ្ឋាន www.hud.gov/offices/hsg/mfh/rhiip/eiv/eivhome.cfm ។